# ព្រះអម្ចាស់នៃចម្រូត ម៉ាថាយ ៩:៣៥-៣៨

នៅពេលដែលខ្ញុំបានចុះតាមក្រុមជំនុំឆ្នាំមុននេះ លោកគ្រូនិមួយៗបានអញ្ជើញខ្ញុំឡើងអធិប្បាយព្រះគម្ពីរ។ ដោយសារខ្ញុំជាបេសកជន ជាគ្រូផ្សព្វផ្សាយដំណឹងល្អព្រះយេស៊ូវគ្រីស្ទ លោកគ្រូទាំងនោះមានបំណងឲ្យខ្ញុំអធិប្បាយអំពីការសរៈសំខាន់នៃការផ្សាយដំណឹងល្អ សម្រាប់ក្រុមជំនុំ។ ក្រុមជំនុំនិមួយៗត្រូវការ ការបង្រៀននិងការដាស់តឿនអំពីការផ្សាយដំណឹងល្អជាញឹកញាប់។ ហេតុអ្វី?

**ពិភាក្សាគ្នាមួយរយៈ** ហេតុខ្លះដែលនាំអ្នកជឿលើព្រះយេស៊ូវឈប់ ឬមិនចាប់ផ្តើមផ្សាយដំណឹងល្អ គឺកំពុងតែដើរតាមលោកិយ ខ្លាចការបៀតបៀន រំខានដោយស្ថានភាពរស់ក្នុងរកស៊ី ថែទាំគ្រួសារ រៀន ឬការរស់ផ្សេងៗទៀតក៏មាន។ ដោយសារតែការរំខានទាំងអស់នេះ យើងត្រូវការការរំលឹក។

**<u>សូមអានព្រះគម្ពីរ</u>** <u>ម៉ាថាយ ៩:៣៥-៣៨ ជាមួយខ្ញុំ</u>

> **<u>35បន្ទាប់មក ព្រះយេស៊ូវយាងទៅគ្រប់ក្រុង គ្រប់ភូមិ ទាំងបង្រៀននៅតាមសាលាប្រជុំរបស់គេ ព្រមទាំងប្រកាសដំណឹងល្អអំពីព្រះរាជ្យ ហើយប្រោសអស់ទាំងជំងឺរោគាគ្រប់ប្រភេទឲ្យបានជា។ 36កាលព្រះអង្គទតឃើញមហាជន ព្រះអង្គមានព្រះហឫទ័យក្តួលអាណិតដល់គេ ព្រោះគេល្វើយ ហើយខ្ចាត់ខ្ចាយ ដូចចៀមគ្មានគង្វាល។ 37ពេលនោះ ទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា៖ «ចម្រូតធំណាស់ តែមានអ្នកច្រូតតិចទេ។ 38ដូច្នេះ ចូរទូលសូមដល់ព្រះអម្ចាស់នៃចម្រូតឲ្យព្រះអង្គចាត់ពួកអ្នកច្រូតមកក្នុងចម្រូតរបស់ព្រះអង្គ»។</u>**

## ខ៣៥ ព្រះយេស៊ូវ ប្រកាសដំណឹងល្អអំពីរព្រះរាជ្យ

នៅពេលដែលយើងអានព្រះបន្ទូលរបស់ព្រះយេស៊ូវតាមដំណឹងល្អ ម៉ាថាយ មាគុស លូកា និងយ៉ូហាន យើងឃើញថា ព្រះអង្គតែងតែប្រកាសថា កែប្រែចិត្ត នគររបស់ព្រះមកជិតបង្កើយ។ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ ជាព្រះគ្រីស្ទ ដែលត្រូវយាងមក។ អស់អ្នកណាដែលកែប្រែចិត្ត ហើយទទួលទ្រង់ត្រូវសង្គ្រោះ  នឹងរួចផុតពីទោសបាប សេចក្តីស្លាប់ និងការរងទុក្ខដែលកើតមានដោយសារអំពើបាប។ ដើម្បីបង្ហាញឲ្យមនុស្សយល់ថា ទ្រង់ជាព្រះដែលសម្រេចទាំងអស់នេះបាន ព្រះអង្គបានប្រោសអស់ទាំងជំងឺរោគាគ្រប់ប្រភេទឲ្យបានជា។

**<u>សូមអានព្រះគម្ពីរ</u>** <u>អេសាយ ៥៣:៤-៥</u> ព្រះបន្ទូលទំនាយអំពីព្រះអង្គសង្គ្រោះដែលត្រូវយាងមក

> **ព្រះអង្គបានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែ យើងរាល់គ្នាបានរាប់ព្រះអង្គទុកជាអ្នកមានទោសវិញ**
>
> **គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងផទនា។ ប៉ុន្តែ ព្រះអង្គត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើព្រះអង្គ ហើយយើងរាល់គ្នាបានប្រោសឲ្យជា**
>
> **ដោយសារស្នាមរំពាត់នៅអង្គទ្រង់។**

ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះដែលបានសម្រេចពាក្យទំនាយនេះ។ ព្រះអង្គបានទទួលទោស និងផលបាបនូវចំនោះយើង ប្រយោជន៍ឲ្យយើងរួចពីពាប សេចក្តីស្លាប់ និងការរងទុក្ខ។

## ខ៣៦ ព្រះអង្គមានព្រះហឫទ័យក្តួលអាណិតដល់គេ

**កាលព្រះអង្គទតឃើញមហាជន ព្រះអង្គមានព្រះហឫទ័យក្តួលអាណិតដល់គេ ព្រោះគេល្វើយ ហើយខ្ចាត់ខ្ចាយ ដូចចៀមគ្មានគង្វាល។**

តើហេតុអ្វីបានជាព្រះយេស៊ូវមានព្រះហឫទ័យអាណិតអាសូរដល់មហាជន?

**ព្រោះគេល្វើយ អស់កម្លាំងល្វើយ** តើពាក្យទាំងនេះសំដៅទៅលើអ្វី? ការរងទុក្ខផ្សេងៗ ការលំបាកនៃជីវិត អស់សង្ឃឹម សាសនាឥតជួយ ផលវិបាកដោយព្រោះបាបខ្លួន ឬអ្នកដទៃ។ល។

**ព្រោះគេស្ចាត់ខ្ចាយ ខ្ចាត់ព្រាត់ ដូចចៀមគ្មានគង្វាល** គ្មានគោលបំណងជីវិត វង់វេង ងាយរងគ្រោះ មិនស្គាល់ព្រះដ៏ជាគង្វាលទេ មានតែខ្លួនឯង និងព្រះខ្លែងខ្លាយ។

<u>**សូមអានព្រះគម្ពីរ យ៉ូហាន ១០:១១, ១៤-១៦**</u>

**11ខ្ញុំជាគង្វាលល្អ គង្វាលល្អហ៊ានប្តូរជីវិតជំនួសចៀមខ្លួន។**

**14ខ្ញុំជាគង្វាលល្អ ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយចៀមរបស់ខ្ញុំក៏ស្គាល់ខ្ញុំដែរ 15គឺដូចជាព្រះវរបិតា**
**ស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់ព្រះអង្គដែរ ខ្ញុំស៊ូប្តូរជីវិតខ្ញុំដើម្បីចៀម។ 16ខ្ញុំនៅមានចៀមឯទៀត ដែល**
**មិនទាន់នៅក្នុងក្រោលនេះនៅឡើយ ខ្ញុំត្រូវតែនាំចៀមទាំងនោះមកដែរ វានឹងស្តាប់តាមសំឡេង**
**ខ្ញុំ។ ដូច្នេះ នឹងមានហ្វូងចៀមតែមួយ មានគង្វាលតែមួយ។**

ព្រះរាជ្យបុត្រាបានយាងមកពីស្ថានសួរដើម្បីគ្វាលកូនចៀមរបស់ព្រះអង្គ។ ឥឡូវនេះ ទ្រង់កម្ពុងតែស្វែងរកចៀមរបស់ព្រះអង្គតាមរយៈអ្នកជឿមុន។ ម៉្យាងកូនចៀមរបស់ព្រះជាសំឡេងដែលព្រះអង្គប្រើដើម្បីនាំចៀមថ្មីចូលក្នុងក្រោល។

**<u>ខ៣៧ មានបញ្ហាធ្ងន់ធ្ងរ គឺចម្រូតធំណាស់ តែមានអ្នកចម្រូតតិចទេ</u>**

**ពេលនោះ ទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា៖ចម្រូតធំណាស់ តែមានអ្នកច្រូតតិចទេ។**

ក្នុងការប្រៀបធៀបរបស់ព្រះអង្គ ពាក្យ **ស្រូវ** សំដៅទៅលើអ្វី? ពាក្យ **ចម្រូត** វិញ?

**ចម្រូតធំណាស់** ការងារច្រូតកាត់មានច្រើន ប៉ុន្តែអ្នកចម្រូតមានតិច។ តើមានអ្វីកើតឡើងបើសិនជាកសិករធ្វេសប្រហែស មិនប្រមូលផលនូវរដូវចម្រូត?

ជំនួនប្រជាជននៅខេត្តពោធិ៍សាត់ គឺ ជៀង***៤២ម៉ឺនអ្នក***!

ជំនួនប្រជាជននៅទីក្រុងពោធិ៍សាត់ គឺ ***ជិត៦ម៉ឺនអ្នក***!

ចម្រូតរបស់ព្រះធំជៀងក្រុមគ្រួសាររបស់យើងដែរ ចម្រូតរួមមានអ្នកភូមិ អ្នកឃុំ អ្នកស្រុក និងអ្នកខេត្តនេះដែរ។

**<u>ខ៣៨ មានដំណោះស្រាយចំពោះបញ្ហាធ្ងន់ធ្ងរនេះ គឺទូលសូមដល់ព្រះអម្ចាស់នៃចម្រូត</u>**

**ដូច្នេះ ចូរទូលសូមដល់ព្រះអម្ចាស់នៃចម្រូត ឲ្យព្រះអង្គចាត់ពួកអ្នកច្រូតមកក្នុងចម្រូតរបស់ព្រះអង្គ។**

ព្រះអង្គមានព្រះរាជ្យបញ្ជាថា **ទូលសូមដល់ព្រះអម្ចាស់នៃចម្រូត។** តើយើងត្រូវទូលសូមអ្វី? **ឲ្យព្រះអង្គចាត់ពួកអ្នកច្រូតមកក្នុងចម្រូតរបស់ព្រះអង្គ។**

**ពិភាក្សាគ្នាមួយរយៈ** តើបងប្អូនគិតយ៉ាងម៉េច? ហេតុអ្វីបានជាព្រះអង្គបានបញ្ជាឲ្យយើងអធិស្ឋានដូចនេះ? ដើម្បីស្គាល់ព្រះហឫទ័យនៃព្រះ យល់អំពីរការសារៈសំខាននៃការផ្សាយដំណឹងល្អ នៅពេលដែលអធិស្ឋានបែបនេះ ព្រះអង្គនឹងនាំព្រះហឫទ័យក្តួលអាណិតរបស់ទ្រង់ចូលក្នុងបេះដូងរបស់យើង លទ្ធផលយើងនឹងចុះទៅក្នុងចម្រូត។

តើបងប្អូនធ្លាប់អធិស្ឋានតាមព្រះរាជ្យបញ្ជានេះទេ? ការអធិស្ឋាននេះ យើងគួរទូលសូមពាក្យនេះញឹកញាប់ដើម្បីចូលរួមជាមួយនឹងទ្រង់ក្នុងចម្រូត។ ព្រះយេស៊ូវកំពុងស្វែងរកចៀមដែលមិនទាន់ចូលក្នុងក្រោលរបស់ព្រះអង្គ។